ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៣ លេខ ១៥ សប្តាហ៍ទី ៤ ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១៣

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃជាវ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់តម្លៃជាវជាមុន)

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

p

ក

មាតិកា

I.~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៤.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០២៦ ស្តីពី ការប្រោសព្រះរាជទាន ជាកិច្ចបច្ឆាមរណៈ ចំពោះសព លោក សួរ្យ និត្យ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ១៦៨៥

២១.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/០៨៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ចាតូបនីយកម្មដល់លោក គីម ជីនយុគ (KIM JINHYUK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា គីម តារា (KIM DARA) ១៦៨៦

២៧.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១១២ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈ ជូនសពលោកឧត្តមសេនីយ៍ត្រី ម៉េង ខូនសីម នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៦៨៧

២៧.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១១៣ ស្តីពី ការកាត់ផ្ទៃដីទំហំ ៤២៤.៤២ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃគូលេន-ព្រហ្មទេព ដែលកំណត់ដោយព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១២ និង ១១១.៦៦ ហិកតា កាត់ចេញពីរមណីយដ្ឋានប្រាសាទព្រះវិហារ ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០១១ ១៦៨៨

២៧.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១១៤ ស្តីពី ការតែងតាំង លោក ឡៃ ជីតេ ជា ឧកញ៉ា ១៦៨៩

២៧.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១១៥ ស្តីពី ការតែងតាំង លោក ស៊ុយ ហេង ជា ឧកញ៉ា ១៦៩០

២៧.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១១៦ ស្តីពី ការតែងតាំង លោកស្រី អៀប ណៃ ជា ឧកញ៉ា ១៦៩១

២៧.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១១៧ ស្តីពី ការតែងតាំងលោកជំទាវ ឈួរ ពេជ្រច័ន្ទបូរមី្ម ជា ទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នីតិកាលទី ៣ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១៦៩២

២៧.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១១៨ ស្តីពី ការតែងតាំង លោក ថៃ ខាន ជា ឧកញ៉ា ១៦៩៣

p

២៧.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១១៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និង សប្បុរសជន ចំនួន ២៨ រូប ១៦៩៤

៣០.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១២០ ស្ដីពី ការកែសម្រួលឋានន្តរស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សមូលដ្ឋាន និង ប្រាក់បំណាច់មុខងារ របស់ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និង ភ្នាក់ងារបច្ចេកទេសរបស់មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ១៦៩៥

៣០.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១២១ ស្ដីពី ការលើកលែងទោសឱ្យទណ្ឌិតឈ្មោះ ពើយ ប៉ែស ១៦៩៨

៣០.០១.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០១១៣/១២២ ស្ដីពី ការលុបឈ្មោះ ឧត្តមសេនីយ៍ត្រី ច័ន្ទ ខណ្ឌៈ ចេញពីក្របខ័ណ្ឌ នៃកងយោធពលខេមរភូមិន្ទ ១៦៩៩

១១.០២.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០២១៣/១២៣ ស្ដីពី ការកាត់ផ្ទៃដីទំហំ ៤៧៤,៨៣ ហិកតា ចេញពីដែនជម្រកសត្វព្រៃណាមល្យៀវ ដែលកំណត់ដោយព្រះរាជក្រឹត្យចុះ ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៦ ១៧០០

១១.០២.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០២១៣/១២៤ ស្ដីពី ការតែងតាំងឯកឧត្តម ម៉ៅ ឡាំង ជាទីប្រឹក្សាអមក្រសួងសាធារណការ និង ដឹកជញ្ជូន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ១៧០១

១១.០២.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០២១៣/១២៥ ស្ដីពី ការតែងតាំងឯកឧត្តមឈួរ ផល្លា ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្ដីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ១៧០២

១១.០២.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០២១៣/១២៦ ស្ដីពី ការតែងតាំង លោកជំទាវ និង អស់លោក ចំនួន ០៣ រូប ជា ឧកញ៉ា ១៧០៣

១១.០២.២០១៣ - ព្រះរាជក្រឹត្យ នស/រកត/០២១៣/១២៧ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ សប្បុរសជន ចំនួន ០៤ រូប ១៧០៤

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

០៦.០២.២០១៣ - អនុក្រឹត្យលេខ ៥៤ អនក្រ.បក ស្ដីពី ការកាត់ដីទំហំសរុប ៤៦៣,៩២ ហិកតា នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ក្នុងនោះកាត់ចេញពីដីសម្បទានសេដ្ឋកិច្ច និង កាត់ចេញពីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ "មណ្ឌលគិរី" និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៩៣ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៧០៥

០៦-០២-២០១៣ - អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពី ការកាត់ដីទំហំសរុប ៦៦៤,០២ ហិកតា នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ក្នុងនោះ កាត់ចេញ ពីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ " មណ្ឌលគិរី " និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៨៣ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៧០៨

០៦-០២-២០១៣ - អនុក្រឹត្យលេខ ៥៦ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៤២៧ ហិកតា នៅស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៨៥ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៧១១

១២-០២-២០១៣ - អនុក្រឹត្យលេខ ៥៧ អនក្រ.បក ស្តីពី ការកាត់ដីទំហំសរុប ៩៥៦,០១ ហិកតា នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ក្នុងនោះកាត់ចេញពី ដែនជម្រកសត្វព្រៃភ្នំណាមលៀរ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច និង កាត់ចេញពីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និង សត្វព្រៃ " មណ្ឌលគិរី " និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៥២ គ្រួសារ និង រក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ ១៧១៥

១២-០២-២០១៣ - អនុក្រឹត្យលេខ ៥៨ អនក្រ.បក ស្តីពី ការកាត់ដីសរុបទំហំ ៥៩៨ ហិកតា នៅស្រុកតំបែរ ខេត្តកំពង់ចាម ក្នុងនោះកាត់ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ និងកាត់ចេញពីព្រៃសម្បទានរបស់ក្រុមហ៊ុន សាមលីញ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៨៥ គ្រួសារ ១៧១៨

១២-០២-២០១៣ - អនុក្រឹត្យលេខ ៥៩ អនក្រ.បក ស្តីពី ការកាត់ដីទំហំ ៦៣៥ ហិកតា នៅ ស្រុកតំបែរ ខេត្តកំពង់ចាម ចេញពីគម្របព្រៃឈើ ឆ្នាំ ២០០២ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤២៨ គ្រួសារ ១៧២១

២២-១១-២០១២ - អនុក្រឹត្យលេខ ២៦២៤ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ១៧២៤

២៣-១១-២០១២ - អនុក្រឹត្យលេខ ២៦២៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ១៧២៥

២៣-១១-២០១២ - អនុក្រឹត្យលេខ ២៦២៦ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៧២៧

២៣-១១-២០១២ - អនុក្រឹត្យលេខ ២៦២៧ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ១៧២៩

២៣-១១-២០១២ - អនុក្រឹត្យលេខ ២៦២៨ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយសសុវត្ថារា ១៧៣១

២៦-១១-២០១២ - អនុក្រឹត្យលេខ ២៦២៩ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៧៣៣

២៦-១១-២០១២ - អនុក្រឹត្យលេខ ២៦៣០ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៧៣៤

២៦-១១-២០១២ - អនុក្រឹត្យលេខ ២៦៣១ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៧៣៥

២៦.១១.២០១២-អនុក្រឹត្យលេខ ២៦៣២ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ១៧៣៦
០៣.១២.២០១២-អនុក្រឹត្យលេខ ២៦៣៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៧៣៧
០៣.១២.២០១២-អនុក្រឹត្យលេខ ២៦៣៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ១៧៣៨
០៣.១២.២០១២-អនុក្រឹត្យលេខ ២៦៣៥ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៧៣៩
០៣.១២.២០១២-អនុក្រឹត្យលេខ ២៦៣៦ អនក្រ.តត ស្តីពី ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ ១៧៤០
០៣.១២.២០១២-អនុក្រឹត្យលេខ ២៦៣៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៧៤១
០៤.១២.២០១២ -អនុក្រឹត្យលេខ ២៦៣៨ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ១៧៤២
០៤.១២.២០១២ -អនុក្រឹត្យលេខ ២៦៣៩ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៧៤៣
០៤.១២.២០១២ -អនុក្រឹត្យលេខ ២៦៤០ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ១៧៤៤
០៤.១២.២០១២ -អនុក្រឹត្យលេខ ២៦៤១ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ១៧៤៦
០៤.១២.២០១២ -អនុក្រឹត្យលេខ **២៦៤២** ដល់អនុក្រឹត្យលេខ **២៦៥០** អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១៧៤៧

២.សេចក្តីសម្រេច

១២.០២.២០១៣-សេចក្តីសម្រេចលេខ ០៤ សសរ ស្តីពី ការបង្កើតគណៈកម្មការសម្រាប់រៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៃអគារសិក្សា អគារនានា ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធរបស់សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ និង អគារសិក្សារបស់វិទ្យាល័យ ហ៊ុន សែន កំចាយមារ ខេត្តព្រៃវែង ១៧៥៦
១៣.០២.២០១៣-សេចក្តីសម្រេចលេខ ០៥ សសរ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មការស្រាវជ្រាវបុរាណវិទ្យានៅស្ថានីយជើងឯក ១៧៥៩

III.ការងារបណ្តាក្រសួង

១.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២២.០១.២០១៣-ប្រកាសលេខ ០៦០ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហុងកុង យូហ្វេង ហ្គាមេន (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ១៧៦២
២៣.០១.២០១៣-ប្រកាសលេខ ០៦៣ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូ នីត (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ១៧៦៦
២៣.០១.២០១៣-ប្រកាសលេខ ០៦៤ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ខៃ យូ (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ១៧៧០

២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

១១.០២.២០១៣-ប្រកាសលេខ ០៣៨ ប្រក ស្ដីពី ការបង្កើតឯកសណ្ឋាន សញ្ញាសក្ដិ និង ស្លាកសញ្ញាសម្គាល់របស់មន្ត្រីក្រសួងទេសចរណ៍ ដែលទទួលនីតិសម្បទាជា នគរបាលយុត្តិធម៌ ១៦៧៤

៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៤-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១០៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេមបូឌាន ហ្គូដ អ៊ីស ១៧៨៦

២៤-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១០៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឌីអេសជីអេស អេនជីនារីង ស៊ីទីស ១៧៨៨

២៤-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១០៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឌូហ្វូន គ្រុប (ខេមបូឌា) ១៧៩០

២៤-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១០៩ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ្វូ ថៃ អ៊ិនវេសមេន ១៧៩២

២៥-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១២៦ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ្វូឌីស ដេន់រ ១៧៩៤

២៥-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១២៧ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ការិយាល័យតំណាងពាណិជ្ជកម្មក្រុមហ៊ុន ហ្គោលដេន យីង ឲ្រដហ្គូត លីមីធីត ១៧៩៦

២៥-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១២៨ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេមបូ ព្រេន ឌីវេឡុបមេន ១៧៩៧

២៥-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៥២ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ការិយាល័យតំណាងពាណិជ្ជកម្មក្រុមហ៊ុន នីបផុន អិចប្រេស (ស៊ីងហ្គាពរ) ភីធីអ៊ី អិលធីឌី ១៧៩៩

២៥-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៥៥ ពណ.ចបព ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អាយធី សំបូត ១៨០០

២៦-៨-២០១១ -លិខិតបញ្ជាក់លេខ ៥១៥៨ ពណ.ចបព ស្ដីពី ការចុះបញ្ជីនូវការបង្កើតសាខា ធនាគារសាយហ្គន ធឿងទីន ពាណិជ្ជ (ធនាគារសាខម) សាខាវេងស្ពានធំនើបឡៅតុណាម ១៨០២

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានគ្គមិជាតិសាសនា រត្តនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាកិច្ចបច្ឆាមរណៈ

ចំពោះសព

លោក ស្នួរ រិន្ទ

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរស.១៣០១.០២៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៣

លេខៈ ១១១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
[illegible] សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/០៩៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **គីម ជីនយុក** (KIM JINHYUK) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៨១ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **គីម តារា** (KIM DARA)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

[illegible] ១៣០១.០៩៦

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០១៣

លេខ ៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទទួលបន្ទុករាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១១២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជាកិច្ចបច្ឆាមរណៈជូនសពលោកឧត្តមសេនីយ៍ត្រី **ម៉េង ខួនលីម** អត្តលេខ ០២១៨១ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៤.១៣០១.១១៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខ ១០០ ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការ[illegible]រាជរដ្ឋាភិបាល

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: កាត់ផ្ទៃដីទំហំ ៤២៤,៤២ ហិកតា ក្នុងនោះ ៣១២,៧៦ ហិកតា កាត់ចេញពីដែនជំរកសត្វព្រៃភ្នំត្បែង-ព្រហ្មទេព ដែលកំណត់ដោយព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១២ និង ១១១,៦៦ ហិកតា កាត់ចេញពីរមណីយដ្ឋានប្រាសាទព្រះវិហារ ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១ ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៩.១៣០១.១១៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

ច.ល
ដើម្បី[illegible]
រាជធានីភ្នំពេញ [illegible] ឆ្នាំ២០១៣
[illegible]រាជរដ្ឋាភិបាល
សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្តមិជាតិសាសនា រត្ននត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

លោក ឡៃ ឌីកេ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស. រកត. ០១១៣. ១១៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខ: ១១៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ក្រាស់បង្គាប់

តែងតាំង :

លោក ស៊ុយ ហេង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ជាលេ.១៣០១.១១៦

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

ប្រេះ ១១៨ ប.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ [illegible] កុម្ភៈឆ្នាំ២០១៣
[illegible]រដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១១៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

លោកស្រី អៀម ណៃ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧០.១៣០១.១១៧

ធ្វើនៅព្រះបរមរាជវាំង.ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខៈ ១១៩ ប.ល
សារៈដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៣
...រាជរដ្ឋាភិបាល

...ស៊យ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកដំបូង នីតិកាលទី៣ នៃព្រឹទ្ធសភា នាថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងលោកជំទាវ **ឈួរ តេជ្រចំន្ទបូរម៉ី** ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

៣រស. ១៣០១.១១៥

លេខៈ ១២០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ២០១៣
អគ្គលេខាធិការរងទី[illegible]រដ្ឋាភិបាល
[illegible] សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ព្រះរាជបញ្ញាស្តីពី?

ព្រាស់បង្គាប់

តែងតាំង :

លោក ថៃ ខាន

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរល.១៣០១.១១៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខៈ ១១៦ ប.ល
ចម្លងចែកជូន
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

មន្ត្រីរាជការ និងសប្បុរសជន ចំនួន ២៨រូប ដែលមានគុណបំណាច់យ៉ាងធំធេងក្នុងការបម្រើជាតិមាតុភូមិ នូវ

ក- គ្រឿងឥស្សរិយយស ជាតូបការ :

១- ឯកឧត្តម ចេង សាខុន

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១- លោក ជួន ប៊ិតថុល
២- លោក ឆឹង ពិសិដ្ឋ

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១- ឯកឧត្តម ព្រហ្ម សារឿន
២- លោក ម៉ី លីហួត
៣- លោក សុខ មុនីរតនា
៤- លោក ឃ្លោក សំអាង
៥- លោក នាដ្ឋ វ៉ាឌុធ
៦- លោក តាត សាឌុន

ឃ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១- លោកជំទាវ ហៃ ស្រីម៉ិន

ង- គ្រឿងឥស្សរិយយ ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១- លោក ហេង ម៉េងហាក់
២- លោក លឹម គ្រឹន
៣- លោកស្រី ខាត់ សុខុម
៤- លោក លី ភាព
៥- លោក ហួង គីមហឿន

ច- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១- លោក ទៀច ចិសិដ្ឋ
២- លោក ប្រាក់ សម្បត្តិ
៣- លោក ថន ផល្លាប
៤- លោក ចិន កុសល
៥- លោក ជា ស៊ីចន្ថា
៦- លោក អៀង ស៊ីណា
៧- លោក ទ្រី សុខ

ឆ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១- លោក ប៉ាន់ សាំង
២- លោក ជា ចំរុង
៣- លោក កេ សៅ
៤- លោក សុខ ប៊ូរិន
៥- លោក លី គីមម៉ាន់

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧រសវ.១៣០១.១២០

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣

លេខ: ៨៧ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៣
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១២០

ស្តីពី

ការកែសម្រួលឋានន្តរស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ របស់ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និងភ្នាក់ងារបច្ចេកទេស របស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០០/១២៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០០/១៣៥ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៤ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌភ្នាក់ងារបច្ចេកទេស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្រោមបន្ទាប់

មាត្រា ១.-

ព្រះរាជក្រឹត្យនេះកំណត់អំពីការកែសម្រួលឡើងវិញនូវឋានន្តរស័ក្តិ ថ្នាក់ សន្ទស្សន៍បៀវត្សមូលដ្ឋាន និងការផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិលក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និងភ្នាក់ងារបច្ចេកទេស ដែលត្រូវបានចាត់ថ្នាក់ក្នុង**ប្រភេទ ឃ** របស់មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២.-

ក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និងភ្នាក់ងារបច្ចេកទេស ដែលស្ថិតក្នុង**ប្រភេទ ឃ** មាន១៤ថ្នាក់ ដោយពុំមានបែងចែកជាឋានន្តរស័ក្តិទេ។

មាត្រា ៣.-

បៀវត្សមូលដ្ឋាននៃក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និងភ្នាក់ងារបច្ចេកទេស ត្រូវបានកំណត់ទៅតាមកម្រិតនៃសន្ទស្សន៍ដូចខាងក្រោម៖

ប្រភេទ	**ថ្នាក់**													
ឃ	១៤	១៣	១២	១១	១០	៩	៨	៧	៦	៥	៤	៣	២	១
សន្ទស្សន៍	១៤៥	១៤៩	១៥៣	១៥៨	១៦៣	១៦៩	១៧៦	១៧៩	១៨៣	១៨៧	១៩០	១៩៣	១៩៥	១៩៧

មាត្រា ៤.-

ថ្នាក់និងឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និងភ្នាក់ងារបច្ចេកទេស ត្រូវបានកែសម្រួលទៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល**ប្រភេទ ឃ**ថ្មី ដូចខាងក្រោម៖

- ឃ.៣.១៤ និងឃ.៣.១៣ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.១៤ថ្មី
- ឃ.៣.១២ និងឃ.៣.១១ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.១៣ថ្មី
- ឃ.៣.១០ និងឃ.៣.៩ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.១២ថ្មី
- ឃ.៣.៨ និងឃ.៣.៧ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.១១ថ្មី
- ឃ.៣.៦ និងឃ.៣.៥ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.១០ថ្មី
- ឃ.៣.៤ និងឃ.៣.៣ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.៩ថ្មី
- ឃ.៣.២ និងឃ.៣.១ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.៨ថ្មី
- ឃ.២.១០ និងឃ.២.៩ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.៧ថ្មី
- ឃ.២.៨ និងឃ.២.៧ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.៦ថ្មី
- ឃ.២.៦ និងឃ.២.៥ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.៥ថ្មី
- ឃ.២.៤ និងឃ.២.៣ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.៤ថ្មី
- ឃ.២.២ និងឃ.២.១ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.៣ថ្មី
- ឃ.១.៦ ឃ.១.៥ និងឃ.១.៤ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.២ថ្មី
- ឃ.១.៣ ឃ.១.២ និងឃ.១.១ចាស់ ត្រូវបានសមាហរណកម្មចូលក្នុង ឃ.១ថ្មី។

មាត្រា ៥.-

មន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌភ្នាក់ងាររដ្ឋបាល ភ្នាក់ងាររដ្ឋបាលក្រសួងមហាផ្ទៃ និងភ្នាក់ងារបច្ចេកទេស ត្រូវបានទទួលប្រាក់បំណាច់មុខងារតែមួយកម្រិត ដែលមានចំនួន២៤ ០០០រៀលក្នុងមួយខែ។

ក្នុងករណីដែលបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងរួចហើយ នឹងមិនត្រូវបានផ្តល់ជូនប្រាក់បំណាច់មុខងារនេះទៀតទេ។

មាត្រា ៦.-

ការកែប្រែប្រាក់បំណាច់មុខងារ ត្រូវធ្វើឡើងដោយអនុក្រឹត្យ។

មាត្រា ៧.-

ព្រះរាជក្រឹត្យនេះ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ តទៅ។

មាត្រា ៨.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៩.-

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០១៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត.០១១៣.០៦១

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្ដីគោរពជូន

សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ដើម្បីស្នើសុំចុះហត្ថលេខា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល

ហត្ថលេខា

សុខ អាន

លេខៈ ១៦៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រត្តខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : លើកលែងទោសឲ្យទណ្ឌិតឈ្មោះ ពើយ ប៉ែល ភេទ ប្រុស អាយុ ៦៦ឆ្នាំ ឃុំខ្លួននៅ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១១ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ក.ល.១៣០១.១២២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣

លេខ: ១១៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ,ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល

ស៊ុយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០១១៣/១២២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជក្រឹត្យ

មាត្រា១ : លុបឈ្មោះ ឧត្តមសេនីយ៍ត្រី ថន់ វណ្ណៈ អត្តលេខ ០១៦៥៩៧ ចេញពីក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខៈ ៦១ ៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល

សយ សុខា

ចារស. ១៣០១.១២៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១២៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទ្រង់ត្រាស់បង្គាប់

មាត្រា ១: កាត់ផ្ទៃដីទំហំ ៨៧៥,៨៣ ហិកតា ចេញពីតំបន់ដែនជម្រកសត្វព្រៃណាមលៀរ ដែលកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ត្រង់មាត្រា ២ ចំណុចទី ២ លេខរៀងទី ១៦ ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចរស.១៣០២.១២៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខៈ ១៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល
ជ័យ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១២៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម **ម៉ៅ ឡាំង** ជាទីប្រឹក្សាអមក្រសួងសាធារណការ និងដឹកជញ្ជូនមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

០១៧. ១៣០២. ១២៥

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

បានយកសេចក្តីក្រាបបង្គំទូល ច.ល
ដើម្បីឡាយព្រះហស្តលេខា
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៣
នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល
ហ៊ុន សែន

បានយកសេចក្តីចម្លងជូន
ឧបនាយករដ្ឋមន្ត្រី
សុខ អាន

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១២៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រត្នត្ដខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្ដម **ហួរ ផល្លា** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្ដីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អនុរដ្ឋលេខាធិការ។

មាត្រា ២: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣: សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៧រល.១៣០៤.១២៦

[illegible] ប.ល
[illegible]បេក
[illegible] ខែ កុម្ភៈ ឆ្នាំ២០១៣
[illegible]រាជរដ្ឋាភិបាល
[illegible] សុខា

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០១៣

p

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១២៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ត្រាស់បង្គាប់

តែងតាំង :

១- លោកជំទាវ គួ ហួងស៊ួន ស៊ីតចំរើន

២- លោកជំទាវ ឆេង សៀង ចិញ្ញហ្វីរ

៣- លោក អៀ ចៀមហេង

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខៈ ១២៧ ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ១៣ [illegible] ២០១៣
អគ្គលេខាធិការរងខុទ្ទកាល័យ [illegible]

សយ សុខា

ព្រះរាជក្រឹត្យ

នស/រកត/០២១៣/១២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ៤រូប ដែលបានលះបង់កំលាំងកាយ ចិត្ត ប្រាជ្ញា ពេលវេលា និងធនធានយ៉ាងច្រើន ដើម្បីបម្រើសកម្មភាពមនុស្សធម៌ របស់កាកបាទក្រហមកម្ពុជា

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

១- ឯកឧត្តមឧកញ៉ា ស៊ុំ គង់ឡើង

២- លោកជំទាវ គួ ហុងស្លួន ស៊ុំគង់ឡើង

៣- លោកជំទាវ ឆេង សៀង ទិញឡាំរ

៤- លោក អៀ ជៀមហេង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចាកបា.១៣០២.១២៩

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣

លេខ: ១៧៩ ច.ល
ចំលងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៥៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំសរុប ៤៦៣,៩២ ហិកតា នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ក្នុងនោះ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ច និងកាត់ចេញពីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ "មណ្ឌលគិរី" និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៥៣ គ្រួសារ និងរក្សាមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០១៥ លស.មគ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគីរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ៥៦៣,៩២ ហិកតា ក្នុងនោះ (១) ទំហំ ២៩,៤៦ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន សេដ្ឋីកុលា ទំហំ ៨១,៨៨ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វ៉ាំណាស៊ី ទំហំ ១៣,៥៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដាក់ឡាក់ និង (២) ទំហំ ៣៣៩,០៥ ហិកតា កាត់ចេញពីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ "មណ្ឌលគីរី" និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ទំហំ ៥៤៦,៥៤ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ១៧,៣៨ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិប៊ូស្រា ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគីរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៣៥៣ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង នៅភូមិប៊ូស្រា ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី ។

p

មាត្រា ៣ ..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគីរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤ ..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគីរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំសរុប ៦៦៤,០២ ហិកតា នៅស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី ក្នុងនោះ កាត់ចេញពីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃ "មណ្ឌលគិរី" និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៨៣ គ្រួសារ និងរក្សាមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នស ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៨ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៧ លស.មគ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគីរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ៦៦៤,០២ ហិកតា ក្នុងនោះ (១) ទំហំ ៩៣,២៨ ហិកតា កាត់ចេញពីតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និង សត្វព្រៃ "មណ្ឌលគីរី" និង (២) ទំហំ ១៧៦,០៥ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន សេដ្ឋីកុលា ទំហំ ១៨,៧៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វ៉ាវ៉ាណាស៊ី ទំហំ ៣៦០,៣៧ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ដាក់ ឡាក់ ទំហំ ១៥,៥៩ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ខេ ភីស និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៦២៨,៣៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ៣៥,៦៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិពូចា ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគីរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ២៨៣ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិពូចា ឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី ។

p

មាត្រា ៣ ..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្ដែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៤ ..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១៣

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
  អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកាត់ដីសរុបទំហំ ៤២៧ ហិកតា នៅស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៨៥ គ្រួសារ និងរក្សាមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៧២ លស ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៨២៧ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៨២៥ ហិកតា សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ០២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្រែវាល ឃុំក្រាំងលាវ ស្រុករលាប្អៀរ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ២៨៥ គ្រួសារ នៅភូមិស្រែវាល ឃុំក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។

មាត្រា ៣ ..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៤ ..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

p

មាត្រា ៥ ..

